សុន្ទរកថារបស់ **ឯកឧត្តម គុម៉ាម៉ារុ យូជិ**
ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

២៩ វិច្ឆកា ២០១៣

**សូមគោរព លោកស្រី យ៉ាម៉ាម៉ូតុ ឆរី នាយិកា ប្រចាំប្រទេសនៃសមាគម សន្តិស្ម័គ្រចិត្ត អន្តរជាតិ**
**សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ ដោយបានចុះហត្ថលេខា លើកិច្ចសន្យាផ្តល់ហិរញ្ញប្បទានឥតសំណង សំរាប់គំរោង "ការលើកស្ទួយមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា" របស់សមាគមសន្តិស្ម័គ្រចិត្តអន្តរជាតិ(SVA) ដែលជាជំនួយហិរញ្ញប្បទានឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

សមាគមសន្តិស្ម័គ្រចិត្តអន្តរជាតិ(SVA) បាននិងកំពុងពង្រីកសកម្មភាពផ្តល់ជំនួយជាច្រើននៅកម្ពុជាអស់រយៈពេលជាង៣០ឆ្នាំមកហើយ។ ហើយក្នុងនាមរដ្ឋាភិបាលជប៉ុន ក៏បាននិងកំពុង បន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយសមាគមនេះផងដែរ។ សមាគមសន្តិស្ម័គ្រចិត្តអន្តរជាតិ(SVA) បាននិងកំពុងធ្វើសកម្មភាពដោយផ្តោតទៅលើ ការគាំទ្រលើការបណ្តុះបណ្តាលធនធានមនុស្សនិង វិស័យអប់រំ ហើយខ្ញុំសង្ឃឹមថា គំរោងលើកនេះ នឹងរួមចំណែកយ៉ាងធំផងដែរ ដល់ការលើកកម្ពស់កំរិតអក្ខរកម្មនៅតំបន់ជនបទ។

នៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលធនធានមនុស្សផងដែរ។ ទន្ទឹមនឹងកិច្ចសហប្រតិបត្តិការផ្តល់ជំនួយទៅលើផ្នែករឹង រួមមាន ការកសាងអគារបឋមសិក្សានិងអនុវិទ្យាល័យ ការកសាងអគារពិសោធន៍ផ្នែកវិទ្យាសាស្រ្តសំរាប់បណ្តុះបណ្តាលបុគ្គលិកសិក្សាជាដើមនោះ រដ្ឋាភិបាលជប៉ុន ក៏បាននិងកំពុងជំរុញការផ្តល់ជំនួយទៅលើផ្នែកទន់ផងដែរ ដូចជា ការបណ្តុះបណ្តាលបុគ្គលិកសិក្សាផ្នែកវិទ្យាសាស្រ្តជាដើម។

លើកនេះ តាមរយៈជំនួយហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុននេះ កិច្ចការដែលSVA នឹងអនុវត្តន៍នោះគឺ ការកសាងមជ្ឈមណ្ឌលសិក្សាសហគមន៍នៅក្នុងតំបន់ជនបទចំនួន២ នៃខេត្តកំពង់ធំ និងខេត្តសៀមរាប។ យោងតាម ជំរឿនប្រជាជនឆ្នាំ២០០៨ ឃើញថាកំរិតអក្ខរកម្មរបស់ប្រជាជនដែលមានអាយុក្រោម១៥ឆ្នាំ គឺមានប្រហែល៩០%នៅតំបន់ទីក្រុង ផ្ទុយទៅវិញគឺមានតែប្រហែល៧៣% ប៉ុណ្ណោះនៅតំបន់ជនបទ ជាពិសេសនោះគឺ កំរិតអក្ខរកម្មរបស់ស្រ្តីនៅតំបន់ជនបទ នៅមានកំរិតទាបគួរអោយ

គាត់សំគាល់។ យើងអាចនិយាយបានថា គំលាតនៃកំរិតអក្ខរកម្មនៅតំបន់ទីក្រុងនិងតំបន់ជនបទ គឺវាឆ្លុះបញ្ចាំងពីគំលាតខុសគ្នានៃកំរិតជីវភាពប្រចាំថ្ងៃ។

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ជាគោលដៅ ក្នុងការលើកកម្ពស់ការអប់រំអក្ខរកម្មចំពោះកុមារ យុវជន និង មនុស្សពេញវ័យ នៅលើកម្មវិធីពង្រីកការអប់រំក្រៅប្រពន្ធនៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ ហើយសំដៅទៅរកការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសំរាប់ការអប់រំអក្ខរកម្មដែលដំណើរការទៅយ៉ាងមានប្រសិទ្ធភាពរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ និងការកសាងមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅទូទាំងប្រទេស។ ហើយគំរោងនេះ ក៏នឹងជំរុញអោយសម្រេចបាននូវគោលដៅទាំងនោះដែរ។

តាមរយៈគំរោងនេះ ប្រជាជនក្នុងឃុំនីពេជ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងប្រជាជនក្នុងឃុំរោងគោ ស្រុកក្រឡាញ់ ខេត្តសៀមរាប ចំនួនប្រហែល៩២០០នាក់ នឹងទទួលបានសមត្ថភាពជាមូលដ្ឋានគ្រឹះដូចជា ចេះគណនា ចេះអាននិងសរសេរ ដោយឆ្លងតាមរយៈការសិក្សាអក្ខរកម្ម។ ជាងនេះទៅទៀត នឹងទទួលបាននូវចំណេះដឹងទាក់ទងនឹងសុខភាពនិងអនាម័យយ៉ាងចាំបាច់ដើម្បីធ្វើការកែលម្អជីវភាពរស់នៅរបស់ពួកគាត់។

ជាចុងក្រោយនេះ ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុននេះ គឺជាជំនួយដែលត្រូវបានផ្តល់ជូនសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជននៅថ្នាក់មូលដ្ឋានដែលអង្គការក្រៅរដ្ឋាភិបាលជប៉ុនជាអ្នកអនុវត្តន៍។ គំរោងដែលបានចុះហត្ថលេខាក្នុងថ្ងៃនេះ នឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនក្នុងតំបន់គោលដៅខាងលើ។ ខ្ញុំសង្ឃឹមថា ក្រោមការសហការគាំទ្រពីមន្ត្រីរដ្ឋបាលពាក់ពន្ធ័ មជ្ឈមណ្ឌលសិក្សាសហគមន៍នេះ នឹងត្រូវបានប្រើប្រាស់យ៉ាងពេញលេញ មានប្រយោជន៍ និងយូរអង្វែង។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!